**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# សេចក្ដីថ្លែងការណ៍របស់ លោកគីថ័រ លយប្រែកត៍ តំណាងពិសេសរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា អំពីជនជាតិភាគតិចមកពីតំបន់ខ្ពង់រាបភាគកណ្ដាលនៃប្រទេសវៀតណាមដែលស្វែងរកសិទ្ធិជ្រកកោន

**២៨ ឧសភា ២០០៥**

តំណាងពិសេសរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា មានសេចក្ដីព្រួយបារម្ភអំពីសេចក្ដីរាយការណ៍ថ្មីៗនេះ ដែលថាមានមន្ត្រីប្រតិបត្តិច្បាប់ និងកងកំលាំងសន្តិសុខបានចូលរួម នៅក្នុងការរំលោភយ៉ាងធ្ងន់ធ្ងរចំពោះកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា ក្នុងនោះរួមមានការបញ្ជូនត្រឡប់ទៅវិញដោយបង្ខំ នូវជនជាតិភាគតិចមកពីតំបន់ខ្ពង់រាបភាគកណ្ដាលនៃប្រទេសវៀតណាមដែលស្វែងរកសិទ្ធិជ្រកកោន (ដែលជាទូទៅ គេស្គាល់ថាអ្នកភ្នំ ) ។ ទាំងសហគមន៍មូលដ្ឋាននានា អង្គការក្រៅរដ្ឋាភិបាលជាតិ និងសមាជិកសារពត៌មានអន្តរជាតិមួយចំនួន សុទ្ធតែបានរាយការណ៍អំពីការរឹតបន្តឹងចំពោះសេរីភាពក្នុងការដើរហើររបស់ជនទាំងនោះ ដោយរួមទាំងការបញ្ជាអោយបិទផ្លូវផង ។ អ្នកស្រុក អ្នកភូមិទាំងឡាយដែលបាននិយាយប្រាប់ដល់អង្គការសិទ្ធិមនុស្សនានានៅក្នុងប៉ុន្មានសប្ដាហ៍ដែលទើបកន្លងទៅនេះបានត្រូវទទួលរងនូវការរំខានពីអាជ្ញាធរមូលដ្ឋាននានា ។

លោកឡយព្រិចបានមានប្រសាសន៍ថា " បរិបទនេះ ជាការគួរអោយព្រួយបារម្ភណាស់ដោយលោករដ្ឋមន្ត្រីក្រសួងការបរទេសបានថ្លែងនៅពេលថ្មីៗនេះថា រដ្ឋាភិបាលនឹងធ្វើការបញ្ជូនអ្នកភ្នំត្រឡប់ទៅវិញដោយចាត់ទុកថា "ជាជនអន្តោប្រវេសន៍ខុសច្បាប់" ដោយមិនអនុញ្ញាតអោយអ្នកទាំងនោះទាក់ទងស្វែងរកសិទ្ធិជ្រកកោននៅក្នុងប្រទេសកម្ពុជា ឬមិនបើកអោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនមានឱកាសធ្វើការពិនិត្យលើការស្នើសុំទាំងនោះទេ " ។ ហើយថា " ជាពិសេសគួរអោយព្រួយបារម្ភដោយលោករដ្ឋមន្ត្រីការបរទេស គួរតែថ្លែងបញ្ជាក់អះអាងជាថ្មីឡើងវិញអំពីការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការគោរពតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ក៏ប៉ុន្តែផ្ទុយទៅវិញ លោកបានថ្លែងចោទ

#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១៦A មហាវិថី ម៉ៅ សេទុង សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧

ប្រកាន់ម្តងហើយម្តងទៀតដោយគ្មានមូលដ្ឋានថា ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដែលជាទីភ្នាក់ងារខាងជនភៀសខ្លួនរបស់ពិភពលោកនេះ កំពុងតែរត់ពន្ធដោយខុសច្បាប់នូវអ្នកស្វែងរកសិទ្ធិជ្រកកោនចូលមកក្នុងប្រទេសកម្ពុជាទៅវិញ " ។

ក្រោយពីត្រូវគេប្រាប់មិនអោយចូលទៅកាន់តំបន់ព្រំដែន ដើម្បីពិនិត្យវាយតំលៃអំពីការស្នើសុំសិទ្ធិជ្រកកោន នៅក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនត្រូវបង្ខំចិត្តបិទការិយាល័យរបស់ខ្លួនប្រចាំខេត្តរតនគីរីកាលពីថ្ងៃទី១០ ខែមេសា ដោយកំណត់អោយធ្វើប្រតិបត្តិការការងាររបស់ខ្លួននៅត្រឹមតែក្នុងរង្វង់ទីក្រុងភ្នំពេញតែប៉ុណ្ណោះ។ ប្រទេសកម្ពុជាគឺជាភាគីមួយនៃអនុសញ្ញា ឆ្នាំ១៩៥១ ស្តីពីជនភៀសខ្លួន និងនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលធានាអំពីសិទ្ធិសេរីភាពក្នុងការដើរហើរ ដែលជាសិទ្ធិមួយ ដែលរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាក៏បានការពារដែរ ។ គោលការណ៍ស្នូលនៃកាតព្វកិច្ចក្នុងការមិនអោយបញ្ជូនត្រឡប់ទៅវិញ ដូចដែលមានចែងនៅក្នុងអនុសញ្ញា ឆ្នាំ១៩៥១ ស្តីពីជនភៀសខ្លួន និងនៅក្នុងពិធីសារ ឆ្នាំ១៩៦៧ ដែលទាក់ទង គឺចាំបាច់តម្រូវអោយមាននីតិវិធីដ៏ត្រឹមត្រូវមួយសំរាប់កំណត់អំពីឋានៈរបស់ជនភៀសខ្លួន ហើយឆ្លងតាមនីតិវិធីនេះ ដើម្បីធ្វើការកំណត់ពីជនទាំងឡាយដែលចាំបាច់ត្រូវការពារ ។ ដោយប្រទេសកម្ពុជានៅមិនទាន់បានកសាងនូវនីតិវិធីសំរាប់កំណត់សិទ្ធិជ្រកកោននៅឡើយនោះ តោងតែអនុញ្ញាតអោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនអាចមានសិទ្ធិជួបប្រស្រ័យ ជាមួយអ្នកដែលស្វែងរកសិទ្ធិជ្រកកោនបាន ដើម្បីអោយប្រទេសកម្ពុជាអនុវត្តអោយបានត្រឹម ត្រូវតាមកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះ។

លោកតំណាងពិសេសសូមអំពាវនាវដល់រដ្ឋាភិបាលអោយចាប់ផ្តើមធ្វើការចចារក្នុងលក្ខណៈស្ថាបនាឡើងវិញជាមួយអង្គការឧត្តមស្នងការអ.ស.ប ទទួលបន្ទុកជនភៀសខ្លួន និងអោយអនុវត្តអោយបានត្រឹមត្រូវតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ជាពិសេសគោលការណ៍ស្នូលស្តីពីការមិនបញ្ជូនអោយត្រឡប់ទៅវិញ ។ ការបញ្ជូនដោយបង្ខំនូវជនភៀសខ្លួន និងអ្នកសុំសិទ្ធិជ្រកកោនទៅកាន់ប្រទេសដែលគេអាចនិងត្រូវទទួលរងនូវទារុណកម្ម និងប្រព្រឹត្តកម្មមិនត្រឹមត្រូវ ក៏ជាការរំលោភលើកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជាត្រង់មាត្រា៣ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំអោយបាត់បង់តម្លៃជាមនុស្សមួយដែរ។